ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

# សេចក្តីជូនព័ត៌មានស្តីពី
# លទ្ធផលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន
# កិច្ចប្រជុំលើកទី១៥របស់ក្រុមប្រឹក្សាសហគមន៍នយោបាយ និងសន្តិសុខអាស៊ាន
# និងកិច្ចប្រជុំលើកទី១៩របស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន
# ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧ ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន

* * * * *

ក្នុងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី១៥ និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី១៩ ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧ ដែលមានឯកឧត្តម **អេនរីក ម៉ាណាឡូ** រដ្ឋមន្ត្រីការបរទេសស្តីទី របស់ហ្វីលីពីន ធ្វើជាប្រធានកិច្ចប្រជុំ។

ក្នុងអំឡុងពេលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន រដ្ឋមន្ត្រីបានពិភាក្សាប្រកបដោយលទ្ធផល ក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ការរក្សាតួនាទីស្នូលរបស់អាស៊ាន ព្រមទាំងការធ្វើឲ្យស៊ីជម្រៅថែមទៀតទំនាក់ទំនងរបស់អាស៊ានជាមួយដៃគូខាងក្រៅ ការអភិវឌ្ឍតំបន់ និងបញ្ហាអន្តរជាតិ ដែលជាផលប្រយោជន៍រួម។

ក្នុងចំណោមបញ្ហាតំបន់ និងអន្តរជាតិដែលបានលើកមកពិភាក្សា រួមមាន ការវិវឌ្ឍនៅឧបទ្វីបកូរ៉េ ស្ថានការណ៍នៅសមុទ្រចិនខាងត្បូង ឧក្រិដ្ឋកម្មឆ្លងដែន ដូចជាចោរសមុទ្រ និងការប្លន់ប្រដាប់អាវុធលើនាវា អំពើហិង្សាជ្រុលនិយម និងអំពើភេរវកម្ម។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានចេញសេចក្តីប្រកាសស្តីពីស្ថានការណ៍នៅឧបទ្វីបកូរ៉េ ដែលមានភ្ជាប់មកជាមួយនេះ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន បានពិភាក្សាការតាមដានការអនុវត្តសេចក្ដីសម្រេចរបស់កិច្ចប្រជុំកំពូលអាស៊ានលើកទី២៨ និង២៩ ដែលបានរៀបចំកាលពីឆ្នាំ២០១៦។ កិច្ចប្រជុំក៏បានពិចារណាពីឯកសារលទ្ធផលនានា រួមមាន សេចក្ដីថ្លែងការណ៍របស់អាស៊ានក្នុងការទទួលស្គាល់តួនាទីមុខងារសាធារណៈ ដែលជាកាតាលីករដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ ក៏ដូចជា របាយការណ៍នានារបស់កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានក៏បានពិភាក្សាពីរបៀបថ្មីក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងសន្និសីទក្រោយកិច្ចប្រជុំជាមួយដៃគូសន្ទនានានា ដែលនឹងប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០១៧ នេះ។

នៅក្នុងអំឡុងពេលកិច្ចប្រជុំទាំងនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានសម្ដែងការរីករាយដែលបានឃើញភាពរីកចម្រើនក្នុងដំណើរការព្រាងលិខិតុបករណ៍ស្ដីពីការការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ ដែលនឹងអាចដាក់សុំការអនុម័ត នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅខែវិច្ឆិកា ខាងមុខនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានធ្វើការផ្ដួចផ្ដើមក្នុងការលើកកម្ពស់ឯកសារនេះពីចំណងកុងសង់ស៊ុសលើផ្នែកសីលធម៌ ទៅជាលិខិតុបករណ៍ដែលមានចំណងផ្លូវច្បាប់។

ចំពោះការកសាងសហគមន៍អាស៊ាន ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានអំពាវនាវដល់រដ្ឋមន្ត្រីការបរទេស ឲ្យផ្ដោតការយកចិត្តទុកដាក់ខ្ពស់ដល់ផែនការការងារដំណាក់កាលទី៣ នៃគំនិតផ្ដួចផ្ដើមសម្រាប់សមាហរណកម្មអាស៊ាន និងផែនការមេស្ដីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ ដែលមានផលប៉ះពាល់ផ្ទាល់ដល់កិច្ចប្រឹងប្រែងរបស់អាស៊ានក្នុងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍។

ពាក់ព័ន្ធដល់ទំនាក់ទំនងអាស៊ាន-សហរដ្ឋអាមេរិក ឯកឧត្តមទេសរដ្ឋមន្ត្រីបានរំលឹកឡើងថា បាប់តាំងពីកិច្ចប្រជុំលើកចុងក្រោយរបស់យើង នៅទីក្រុងប៉ូរ៉ាកាយ កាលពីខែកុម្ភៈ យើងនៅមិនទាន់យល់ច្បាស់ពីនយោបាយការបរទេសរបស់អាមេរិកចំពោះអាស៊ីប៉ាស៊ីហ្វិក ជាពិសេសចំពោះអាស៊ាន។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានថ្លែងថា "ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំជឿជាក់ថា ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-អាមេរិកនឹងនៅតែជាអាទិភាព ដោយពិនិត្យដល់សារសំខាន់ភូមិសាស្ត្រនយោបាយ និងសក្ដានុពលសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលកាន់តែកើនឡើង នៅក្នុងតំបន់ និងក្រៅតំបន់"។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានលើកឡើងថា "ក្នុងន័យនេះ ខ្ញុំទន្ទឹងរង់ចាំចូលរួមកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-អាមេរិក នៅទីក្រុងវ៉ាស៊ីងតោន នៅថ្ងៃទី ៤ ខែឧសភា នេះ ដោយសង្ឃឹមថា អាស៊ាន និងសហរដ្ឋអាមេរិក អាចបញ្ជាក់ជាថ្មីអំពីឆន្ទៈរួម និងដ៏រឹងមាំដើម្បីបន្តពង្រឹងភាពជាដៃគូនេះឲ្យកាន់តែជិតស្និត។

ចំពោះតួនាទីស្នូលរបស់អាស៊ានក្នុងនិម្មាបនកម្មតំបន់ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានគូសបញ្ជាក់ថា បច្ចុប្បន្ន ពិភពលោកកំពុងឆ្លងកាត់ដំណាក់កាលដ៏សំខាន់នៃការផ្លាស់ប្ដូរទំនាក់ទំនងអំណាច ដោយបានគូសបញ្ជាក់ថា "យើងគួរតែបន្តរក្សាតួនាទីស្នូលរបស់អាស៊ាន ការឯកភាព និង

សាមគ្គីភាព។ ចំពោះកម្ពុជា ជំហរដ៏ច្បាស់លាស់របស់យើងគឺៈ យើងគោរពទៅតាមគោលការណ៍ស្នូលនៃធម្មនុញ្ញអាស៊ាន ដែលរក្សានិងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព ព្រមទាំងបន្តពង្រឹងគុណតម្លៃដែលផ្តោតទៅលើសន្តិភាព នៅក្នុងតំបន់។

ចំពោះបញ្ហាឧបទ្វីបកូរ៉េ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានបញ្ជាក់ថា ស្ថានភាពឧបទ្វីបកូរ៉េកំពុងតែជុនជាបខ្លាំង ដោយកូរ៉េខាងជើងបានសាកល្បងបាញ់មីស៊ីលរយៈឆ្ងាយ និងការសាកល្បងអាវុធនុយក្លេអ៊ែរ។ ដូចគ្នានេះដែរ ការដាក់តម្លើងប្រព័ន្ធការពារមីស៊ីល នៅកូរ៉េខាងត្បូង និងការកើនឡើងនូវវត្តមាននៃកងនាវាប្រយុទ្ធសហរដ្ឋអាមេរិក កំពុងតែបង្កើតនូវភាពតានតឹងក្តៅគគុកនៅក្នុងតំបន់។ បើទោះបីការរំពឹងថានឹងមានសង្គ្រាមទ្រង់ទ្រាយធំមិនអាចកើតមានក៏មានដោយ ហេតុការណ៍នេះកំពុងបង្កការគំរាមគំហែងធ្ងន់ធ្ងរដល់សន្តិភាព សន្តិសុខ និងស្ថិរភាព មិនត្រឹមតែនៅក្នុងឧបទ្វីបកូរ៉េប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល និងតំបន់អាស៊ានផងដែរ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបន្តគូសបញ្ជាក់ថា "ខ្ញុំយល់ស្របជាមួយរដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ីក្នុងការព្យាយាមបញ្ជូនសារទៅរដ្ឋមន្ត្រីការបរទេសអាមេរិកថា សហរដ្ឋអាមេរិកក៏ត្រូវពិចារណាក្នុងការបន្ធូរបន្ថយភាពតានតឹងផងដែរ"។ កម្ពុជាអះអាងជាថ្មី នូវការគាំទ្ររបស់ខ្លួនសម្រាប់ការលុបបំបាត់អាវុធនុយក្លេអ៊ែរនៅក្នុងតំបន់។ ប្រមុខដឹកនាំអាស៊ានចូលរួមជាមួយសហគមន៍អន្តរជាតិ ដោយធ្វើឲ្យប្រាកដថាកូរ៉េខាងជើងត្រូវតែគោរពតាមទាំងស្រុងនូវសេចក្តីសម្រេចពាក់ព័ន្ធផ្សេងៗ របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ និងបោះបង់ ការព្យាយាមបង្កើតអាវុធនុយក្លេអ៊ែររបស់ខ្លួន។

ពាក់ព័ន្ធនឹងការវិវឌ្ឍនៃសមុទ្រចិនខាងត្បូង ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានសង្កេតឃើញថា "ស្ថានភាពបច្ចុប្បន្នមានសភាពស្ងប់ស្ងាត់ ជាពិសេស បន្ទាប់ពីការអនុម័តសេចក្តីប្រកាសរួមស្តីពីការអនុវត្តន៍ក្រមសម្រាប់ការពើបប្រទះដោយមិនបានគ្រោងទុកនៅលំហសមុទ្រ (CUES) និងការបង្កើតខ្សែទូរស័ព្ទពិសេសរវាងក្រសួងការបរទេសនៃប្រទេសអាស៊ាននិងចិន និងវឌ្ឍនភាពជាវិជ្ជមាន និងដំណើរការនៃកិច្ចសន្ទនារវាងប្រមុខដឹកនាំនៃភាគីពាក់ព័ន្ធផ្ទាល់"។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានអំពាវនាវឲ្យភាគីពាក់ព័ន្ធផ្ទាល់ដោះស្រាយជម្លោះដោយសន្តិវិធី តាមរយៈការពិគ្រោះយោបល់ និងការចរចា និងបានស្នើថា គួរចាប់យកវឌ្ឍនភាពជាវិជ្ជមាននេះ ដើម្បីបង្កើនល្បឿនដំណើរការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង (COC) ដើម្បីដាក់ចេញនូវយន្តការមួយដ៏មានប្រសិទ្ធភាព និងរឹងមាំ ក្នុងការឆ្លើយតបទៅនឹងកម្លាំងប្រែប្រួលភូមិសាស្ត្រនយោបាយថ្មី នៅសមុទ្រចិនខាងត្បូង។៚

ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៧